ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំរឿងព្រហ្មទណ្ឌ
លេខ ៥០៦ / ១៥-០៦-២០១១
សាលដីកា
លេខ ៥០ "ក្រ.III.ច" / ២៦-១០-២០១២

# តាងនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍ ភ្នំពេញ

បង្កើតតាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ដែលប្រកាសឲ្យប្រើតាមក្រិត្យលេខ០០៦ក្រ ចុះថ្ងៃទី ០៨-០២-១៩៩៣ បើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍ នៅថ្ងៃទី ០៥-១០-២០១២ ដោយមានសមាសភាពដូចតទៅ:

**សមាសភាពក្រុមប្រឹក្សាជំនុំជំរះ**

លោកស្រី [redacted] ជាប្រធានក្រុមប្រឹក្សា
លោក [redacted] ជាចៅក្រមប្រឹក្សា
លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted] ជាព្រះរាជអាជ្ញា

**ក្រឡាបញ្ជី**

លោក [redacted]

ដើម្បីជំនុំជំរះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ ៥០៦ ចុះថ្ងៃទី ១៥-០៦-២០១១ ដោយមាន៖

**១-ជនជាប់ចោទឈ្មោះ [redacted] ដារ៉ា** ភេទប្រុស អាយុ ៣៨ ឆ្នាំ ជនជាតិខ្មែរ កើតនៅភូមិបត់តានី ឃុំសុភមង្គល ស្រុកតាខ្មៅ ខេត្តកណ្តាល មុខរបររត់ម៉ូតូឌុប សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃភូមិ [redacted] ឪពុកឈ្មោះ [redacted] «ស» ម្តាយឈ្មោះ [redacted] «រ» ប្រពន្ធ ឈ្មោះ [redacted] មានកូន ០៣ នាក់ ទោសពីមុនគ្មាន «ឃុំខ្លួនថ្ងៃទី ២៩-១០-២០០៩»។





Scanned with CamScanner

-បានបោះបង់ការការពារសិទ្ធិលោក [redacted] ម៉ាច ។

ជាប់ចោទពីបទ: នាំចេញដោយមិនស្របច្បាប់សំរាប់ឆ្លងដែន ប្រព្រឹត្តនៅគីរីវង្ស ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង កាលពីថ្ងៃទី ២៧-១០-២០០៩ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ១១ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងធ្វើអាជីវកម្មផ្លូវភេទ។

**២-ដើមបណ្តឹងឈ្មោះ** [redacted] ភេទស្រីអាយុ ២១ឆ្នាំ ជនជាតិខ្មែរ មុខរបរស្រីលក់ខ្លួន កើតនៅភូមិត្រពាំងសាលា ឃុំព្រះនិទាន ស្រុកបសេដ ខេត្តកំពង់ស្ពឺ [redacted] ឪពុកឈ្មោះ [redacted] «រ» ម្តាយឈ្មោះ [redacted] «រ» នៅលីវ។

## ឯរឿងហេតុមានដូចតទៅ៖

កាលពីថ្ងៃទី ២៦-១០-២០០៩ វេលាម៉ោងប្រហែល ៨,០០ព្រឹក ឈ្មោះ [redacted] សុខុម ហៅ យាយម៉ាប់ បាននាំឈ្មោះ [redacted] ដានី ពីរាជធានីភ្នំពេញ មកខេត្តកោះកុង។ លុះដល់ម៉ោង ៦,០០ល្ងាចថ្ងៃដដែល ឈ្មោះ [redacted] សុខុម ហៅ យាយម៉ាប់ និងស្ត្រីម្នាក់ទៀតមិនមានសារគាជាតិ បានឱ្យក្មេងប្រុសជំទង់ម្នាក់នាំឈ្មោះ [redacted] ដានី ជិះអូប៉ីរទៅចំណុចគិរីវង្ស ស្ថិតនៅក្នុងឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង។ ស្អែកឡើងក្មេងប្រុសម្នាក់នោះបាននាំឈ្មោះ [redacted] ដានី ទៅជួប ឈ្មោះ [redacted] គឹម និងប្តីឈ្មោះ [redacted] ដារ៉ា ដែលរស់នៅប្រទេសថៃ ហើយមកចាំទទួលយកឈ្មោះ [redacted] ដានី នៅច្រកព្រំដែនកម្ពុជា-ថៃ (ចំណុចគិរីវង្ស)។ ពេលនោះឈ្មោះ [redacted] ដានី ដោយមានការសង្ស័យក៏បានប្តឹងសមត្ថកិច្ច ហើយក៏ចាប់ខ្លួនបានម្នាក់ឈ្មោះ [redacted] ដារ៉ា រីឯឈ្មោះ [redacted] គឹម និងក្មេងប្រុសជំទង់នោះបានរត់ចូលព្រៃគេចខ្លួនបាត់តែម្តង។ ក្រោយមកក៏ចាប់បានស្ត្រីម្នាក់ទៀត ឈ្មោះ [redacted] សុខុម ហៅ យាយម៉ាប់ ។

-**បានឃើញ**សាលក្រមព្រហ្មទណ្ឌលេខ ១៩ (ឃ) ចុះថ្ងៃទី ០៩-០៣-២០១១ របស់សាលាដំបូងខេត្តកោះកុង សំរេច៖

១-ផ្តន្ទាទោសលើឈ្មោះ [redacted] ដារ៉ា ភេទប្រុស, ឈ្មោះ [redacted] សុខុម ភេទស្រី និងឈ្មោះ [redacted] គឹម ភេទ ស្រី ដាក់ពន្ធនាគារកំណត់ក្នុងម្នាក់ៗរយៈពេល ០៨ ឆ្នាំ (ប្រាំបីឆ្នាំ) ពីបទ: នាំយកចេញដោយមិនស្របច្បាប់សំរាប់ឆ្លងដែន ប្រព្រឹត្តនៅចំណុចគិរីវង្ស ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង កាលពីថ្ងៃទី ២៧-១០-២០០៩ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ១១ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរ មនុស្ស និងធ្វើអាជីវកម្មផ្លូវភេទ។

២-បង្គាប់ឱ្យចាប់ និងឃុំខ្លួនឈ្មោះ [redacted] គឹម ភេទស្រី អាយុ ៣៩ឆ្នាំ ជាតិខ្មែរ របររកស៊ីលក់ដូរ កើតនៅភូមិក្តុង ឃុំឫស្សីស្រុក ស្រុកកំពង់ត្រាច ខេត្តកំពត សាសនាព្រះពុទ្ធ មានទី



Scanned with CamScanner

ល់នៅសព្វថ្ងៃភូមិស្ទឹងវែង សង្កាត់ស្ទឹងវែង ក្រុងខេមរភូមិន្ទ ខេត្តកោះកុង ឪពុកឈ្មោះ [redacted] ·ស· ម្ដាយឈ្មោះ [redacted] ·រ· ប្ដី ឈ្មោះ [redacted] មានកូន ៣នាក់។

៣-សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី ២៣-០២-២០១១ ចំពោះមុខមេធាវីជនជាប់ចោទ និងមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី, ជនជាប់ចោទឈ្មោះ [redacted] ដារ៉ា និងឈ្មោះ [redacted] សុខុម ,កំបាំមុខ ជនជាប់ឈ្មោះ [redacted] គឹម និងឈ្មោះ [redacted] ដានី និងប្រកាសជាសាធារណៈ នៅថ្ងៃទី ០៤-០៣-២០១១ ចំពោះមុខជនជាប់ចោទ មេធាវីជនជាប់ចោទ មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី, ជនជាប់ចោទឈ្មោះ [redacted] ដារ៉ា, ឈ្មោះ [redacted] សុខុម កំបាំងមុខឈ្មោះ [redacted] គឹម និងឈ្មោះ [redacted] ដានី។ បើកផ្លូវប្ដឹងតវ៉ា ក្នុងកំណត់ច្បាប់។

**បានឃើញ**ពាក្យបណ្ដឹងឧទ្ធរណ៍លេខ ១២ ចុះថ្ងៃទី ០៤-០៤-២០១១ របស់ជនជាប់ចោទឈ្មោះ ជូន ដារ៉ា ប្ដឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១៩ "ឃ" ចុះថ្ងៃទី ០៤-០៣-២០១១ របស់សាលាដំបូងខេត្តកោះកុង ត្រង់ចំណុចទាំងមូលនៃសាលក្រមខាងលើ។

**បានឃើញ**របាយការណ៍រឿងព្រហ្មទណ្ឌរបស់ចៅក្រមរបាយការណ៍សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ ។

**បានឃើញ**សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ ។

**នាពេលសវនាការ**

**ប្រធានក្រុមប្រឹក្សាជំនុំជំរះ បានអានរបាយការណ៍សង្ខេបនៃរឿង**

ក្រឡាបញ្ជីបានអានចម្លើយជនជាប់ចោទ ដើមបណ្ដឹងរដ្ឋប្បវេណី និងសាក្សី ។

**តំណាងមហាអយ្យការធ្វើសេចក្ដីសន្និដ្ឋាន**

ជាបទល្មើសជាក់ស្ដែង ជនជាប់ចោទមានគោលបំណងនាំឆ្លងដែនខុសច្បាប់ សុំតម្កល់សាលក្រមរបស់សាលាដំបូង ។

**មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទធ្វើសេចក្ដីសន្និដ្ឋាន**

កូនក្ដីខ្លួនមិនបានប្រព្រឹត្តបទល្មើសអ្វីទេ នៅពេលកើតហេតុកូនក្ដីខ្លួនមិនបានមកសួរនាំជនរងគ្រោះពីបញ្ហាមកប្រទេសថៃទេ នៅពីនោះកូនក្ដីខ្លួនឈរនៅឆ្ងាយពីកន្លែងកើតហេតុ ប្រពន្ធកូនក្ដីខ្លួនជាអ្នកមកសួរនាំ ។ សុំលើកលែងការចោទប្រកាន់ ។

**តុលាការជយនៅពិភាក្សា**

ក្រោយពីបានពិនិត្យឯកសារក្នុងសំណុំរឿងហើយ។

ក្រោយពីបានស្ដាប់តំណាងមហាអយ្យការសន្និដ្ឋាន។

ក្រោយពីបានស្ដាប់ការសន្និដ្ឋានរបស់មេធាវី។



Scanned with CamScanner

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១៩ "ឃ" ចុះថ្ងៃទី ០៤-០៣-២០១១ របស់សាលាដំបូងខេត្តកោះកុង ទុកជាបានការដដែល ។

៣-បន្តឃុំខ្លួនជនជាប់ចោទឈ្មោះ [redacted] ដារ៉ា តាមច្បាប់។

៤-សាលដីកានេះជំនុំជំរះជាសាធារណៈនៅថ្ងៃទី ០៥-១០-២០១២ ប្រកាសជាសាធារណៈនៅថ្ងៃទី ២៦-១០-២០១២ កំបាំងមុខជនជាប់ចោទ បើកសិទ្ធិប្ដឹងតវ៉ាក្នុងកំណត់ច្បាប់។-៤

សេចក្ដីនេះ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ គ្រប់តំណែង និងកងកំលាំងប្រដាប់អាវុធ ជួយសហការអនុវត្តសាលដីកានេះឱ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជំរះ |
|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] |

បានចំលងត្រឹមត្រូវតាមច្បាប់ដើម

សាលាឧទ្ធរណ៍ ថ្ងៃទី ០៧ ខែ ១២ ឆ្នាំ២០១៣

| បានឃើញ | |
|---|---|
| ប្រធានសាលាឧទ្ធរណ៍ | ក្រឡាបញ្ជី |
| [redacted] | [redacted] |



Scanned with CamScanner